ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣១សស

# សេចក្តីថ្វាយ និងជូនដំណឹង

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមក្រាបបង្គំទូលថ្វាយ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជម្រាបជូន បងប្អូនជនរួមជាតិ និងប្រិយមិត្តបរទេសទាំងអស់ សូមព្រះមេត្តាជ្រាប និងសូមមេត្តាជ្រាបថា៖

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គបានយាងចូលព្រះទីវង្គត់ នៅថ្ងៃ ១៥ រោជ ខែភទ្របទឆ្នាំរោងចត្វាស័ក ព.ស. ២៥៥៦ត្រូវនឹងថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០១:២០ នាទីរំលងអធ្រាត (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ នៅមន្ទីរពេទ្យទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងដង្ហែព្រះសពពីសាធារណរដ្ឋប្រជាមានិតចិនមកកាន់រាជធានីភ្នំពេញ ដើម្បីតម្កល់ និងប្រារព្ធព្រះរាជពិធីបុណ្យតាមប្រពៃណីជាតិនៅព្រះបរមរាជវាំង។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ និងជូនបងប្អូនជនរួមជាតិនិងប្រិយមិត្តបរទេសទាំងអស់សូមព្រះមេត្តាជ្រាបនិងសូមមេត្តាជ្រាប។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០១២